ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១០

## សេចក្ដីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបដិសេធច្រានចោលបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ន ដែលប្ដឹងដោយ អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ

នៅក្នុងសេចក្ដីសម្រេចទាំងបី ដែលបានអនុលោម នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបដិសេធច្រានចោលបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ន ដែលបានប្ដឹងដោយជនត្រូវចោទ អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ។

**អៀង សារី :**

អៀង សារី ដែលមានតួនាទីជារដ្ឋមន្ត្រីក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មនុស្សឃាដ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញទៅលើសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (សំណុំរឿងនេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ គាត់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ និងបានដាក់ឃុំខ្លួនបណ្ដោះអាសន្ន ដំបូងគឺមានរយៈពេល១ ឆ្នាំ។ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ត្រូវបានបន្លាយពេល២ដងរួចមកហើយ ដោយចេញដីកាពីសហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសម្ដងកាលពីថ្ងៃ ទី១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងម្ដងទៀតកាលពីថ្ងៃ ទី១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

នៅក្នុងសាលដីកាសម្រេច បដិសេធច្រានចោលបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹង ការបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្នអង្គបុរេជំនុំជម្រះ បានយល់ឃើញថា ការបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការដ៏ចាំបាច់ដើម្បីទប់ស្កាត់ជនត្រូវចោទកុំឲ្យគេចខ្លួន។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះគិតថា ការបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ននេះ គឺចាំបាច់ដើម្បីការពារសន្តិសុខជូនជនត្រូវចោទ ព្រមទាំងដើម្បីរក្សាសន្តិសុខសាធារណៈ។ ការបដិសេធច្រានចោលបណ្ដឹងឧទ្ធរណ៍នេះ មានន័យថា ជនត្រូវចោទ អៀង សារី ប្រហែលនឹងអាចបន្តថេរវេលាឃុំខ្លួនបណ្ដោះអាសន្ន រហូតដល់ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១០ លើកលែងតែ សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយមួយ មុនកាលបរិច្ឆេទខាងលើនេះ។

សេចក្ដីសង្ខេបនៃសាលដីកាសម្រេចនេះ ត្រូវបានអានដោយប្រធានអង្គបុរេជំនុំជម្រះ ឯកឧត្ដម ប្រាក់ គឹមសាន ក្នុងកំឡុងពេលសវនាការសាធារណៈនាថ្ងៃនេះ។

សាលដីកាជាលាយលក្ខណ៍អក្សរ នឹងដាក់បង្ហាញតាមរយៈ
http:///www.eccc.gov.kh/english/court_doc.list.aspx?courtDcoCat=ptc_docs

**ខៀវ សំផនៈ**

ខៀវ សំផន ដែលមានតួនាទីជាប្រមុខរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មនុស្សឃាដ ការធ្វើទារុណកម្មនិងការធ្វើទុក្ខបុកម្នេញទៅលើសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (សំណុំរឿងនេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ គាត់ត្រូវបានចាប់ខ្លួន និងបានដាក់ឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដំបូងគឺមានរយៈពេល១ ឆ្នាំ។ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវបានបន្លាយពេល២ដងរួចមកហើយ ដោយចេញដីកាពីសហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសម្តងកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និង ម្តងទៀតកាលពីថ្ងៃ ទី១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

ការបដិសេធច្រានចោលបណ្តឹងឧទ្ធរណ៍នេះ មានន័យថា ជនត្រូវចោទ ខៀវ សំផន ប្រហែលនឹងអាចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ លើកលែងតែ សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយមួយ មុនកាលបរិច្ឆេទខាងលើនេះ។

នៅក្នុងសាលដីកាសម្រេចបដិសេធច្រានចោលបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា ការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ននេះ គឺចាំបាច់ដើម្បីការពារសុវត្ថិសុខជូនជនត្រូវចោទ ព្រមទាំងដើម្បីរក្សាសុវត្ថិសុខសាធារណៈ។

សេចក្តីសង្ខេបនៃសាលដីកាសម្រេចនេះ ត្រូវបានអានដោយប្រធានអង្គបុរេជំនុំជម្រះ ឯកឧត្តម ប្រាក់ គឹមសាន ក្នុងកំឡុងពេលសវនាការសាធារណៈនាថ្ងៃនេះ។

សាលដីកាជាលាយលក្ខណ៍អក្សរ នឹងដាក់បង្ហាញតាមរយៈ
http:///www.eccc.gov.kh/english/court_doc.list.aspx?courtDcoCat=ptc_docs

**អៀង ធីរិទ្ធៈ**

អៀង ធីរិទ្ធ ដែលមានតួនាទីជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មនុស្សឃាដ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញទៅលើសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (សំណុំរឿងនេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ គាត់ត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ និងបានដាក់ឃុំខ្លួនបណ្តោះអាសន្ន ដំបូងគឺមានរយៈពេល១ ឆ្នាំ។ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវបានបន្លាយពេល

២ដងរួចមកហើយ ដោយចេញដីកាពីសហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសម្តង កាលពីថ្ងៃ ទី១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងម្តងទៀតកាលពីថ្ងៃ ទី១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

ការបដិសេធច្រានចោលបណ្តឹងឧទ្ធរណ៍នេះ មានន័យថា ជនត្រូវចោទ អៀង ធីរិទ្ធ ប្រហែលនឹងអាចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១០ លើកលែងតែ សហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយមួយ មុនកាលបរិច្ឆេទខាងលើនេះ។

នៅក្នុងសាលដីកាសម្រេច បដិសេធច្រានចោលបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹង ការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នអង្គបុរេជំនុំជម្រះ បានយល់ឃើញថា ការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន នៅតែជាវិធានការដ៏ចាំបាច់ដើម្បីទប់ស្កាត់កុំឲ្យជនត្រូវចោទ គាបសង្កត់សាក្សី ឬបំផ្លាញភស្តុតាងចោល។

លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះគិតថា ការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ននេះ គឺចាំបាច់ដើម្បីទប់ស្កាត់ជនត្រូវចោទកុំឲ្យគេចខ្លួន និងដើម្បីរក្សាសុន្តិសុខសាធារណៈ។

សេចក្តីសង្ខេបនៃសាលដីកាសម្រេចនេះ ត្រូវបានអានដោយប្រធានអង្គបុរេជំនុំជម្រះ ឯកឧត្តម ប្រាក់ គឹមសានក្នុងកំឡុងពេលសវនាការសាធារណៈនាថ្ងៃនេះ។

សាលដីកាជាលាយលក្ខណ៍អក្សរ នឹងដាក់បង្ហាញតាមរយៈ:

http:///www.eccc.gov.kh/english/court_doc.list.aspx?courtDcoCat=ptc_docs

**អានុភាពនៃដីកាដំណោះស្រាយ**

ប្រសិនបើសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយមួយ មុនកាលបរិច្ឆេទសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នខាងលើ នោះការចេញដីកានេះ នឹងនាំមកនូវការបញ្ចប់នៃថេរវេលាឃុំខ្លួននាពេលបច្ចុប្បន្ននេះ។

ប្រសិនបើ ដីកាដំណោះស្រាយបូកបញ្ចូលដីកាបញ្ជូនរឿងទៅជំនុំជម្រះលើជនត្រូវចោទ និងសហចៅក្រមស៊ើបអង្កេត ពិចារណាឃើញថា ល័ក្ខខ័ណ្ឌសម្រាប់ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងវិធានផ្ទៃក្នុងទី៦៣ របស់ អ.វ.ត.ក នៅតែមានប្រសិទ្ធិភាព សហចៅក្រមស៊ើបអង្កេត អាចចេញដីកាឲ្យជនត្រូវចោទជាប់ឃុំបណ្តោះអាសន្ន រហូតដល់ ជនត្រូវចោទ ត្រូវបាននាំមកជំនុំជម្រះដោយអង្គជំនុំជម្រះសាលាដំបូង។

ក្នុងករណីនេះ ប្រសិនបើជនត្រូវចោទ មិនត្រូវនាំមកជំនុំជម្រះដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈ៤ខែនោះទេ ដោយគិតចាប់ពីពេលកំណត់ចេញដីកាដំណោះស្រាយ នោះការឃុំខ្លួនបណ្តោះអាសន្ននឹងអស់ប្រសិទ្ធិភាព។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 0៩៤

ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org